ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៨០ សហវ ១៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៤

# ប្រកាស

ស្តីពី

## បែបបទនៃការដោះដូរអចលនទ្រព្យរបស់រដ្ឋ នៅតាមបណ្តាក្រសួង ស្ថាប័ន និង ខេត្ត ក្រុង

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស / ៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

-យោងអនុក្រឹត្យ លេខ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

-យោងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ៣០ប.ប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥

-យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤

-យោងតាមតំរូវការចាំបាច់

### សំរេច

**ប្រការ ១** : រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋ "ដីទំនេរ ដី និង អាគាររបស់រដ្ឋ" ត្រូវអនុវត្តតាមដំណើរការឯកជនភាវូបនីយកម្ម របស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ។

**ប្រការ ២** : រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋ "ដីទំនេរ ដី និង អាគាររបស់រដ្ឋ" ត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃជាសាធារណៈ ដោយត្រូវដេញថ្លៃទាំងអចលនទ្រព្យរបស់រដ្ឋ និង សំណង់ថ្មីដែលជាថ្នូររបស់ឯកជន ។

**ប្រការ ៣** : ចំណូលដែលបានមកពីការដេញថ្លៃលក់អចលនទ្រព្យរបស់រដ្ឋ ត្រូវដកល់នៅគណនីឯកជនភាវូបនីយកម្ម សំរាប់យកទៅទូទាត់ ថ្លៃសំណង់ថ្មីដែលត្រូវសាងសង់ដោយឯកជន ឬ រួមទាំងថ្លៃទីតាំងដីថ្មីរបស់ឯកជន ។

**ប្រការ ៤ :** ចំណូលដែលបានមកពីការលក់អចលនទ្រព្យរដ្ឋនេះ និង ចំណាយទូទាត់ថ្លៃសំណង់ថ្មីដែលត្រូវផ្តល់ដោយឯកជន ឬ រួមទាំងថ្លៃទីតាំងដីថ្មីរបស់ឯកជន ត្រូវឆ្លុះបញ្ចាំងក្នុងប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋ ស្របតាមបទប្បញ្ញត្តិ និង នីតិវិធីជាធរមាន ។

**ប្រការ ៥ :** ក្រសួងរៀបចំដែនដី នគូបនីយកម្ម និង សំណង់ និង មន្ទីររៀបចំដែនដី នគូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង អាចផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យរបស់រដ្ឋជូនភាគីឯកជនបាន លុះត្រាតែមានការសំរេចជាគោលការណ៍ចុងក្រោយពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បន្ទាប់ពីភាគីឯកជនបានបង់ប្រាក់ថ្លៃទិញអចលនទ្រព្យ បានគ្រប់ចំនួនតាមកំណត់ហេតុដេញថ្លៃ ចូលថវិការដ្ឋតាមគណនីលេខ 02-35.1211-T020 នៅធនាគារជាតិនៃកម្ពុជា ព្រមទាំងភាគីឯកជនបានបំពេញកាតព្វកិច្ច ដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងទីតាំងដែលដេញថ្លៃបាននោះរួចរាល់ជាស្ថាពរ ។

**ប្រការ ៦ :** គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ព្រមទាំងនាយកដ្ឋានជំនាញ និង មន្ទីរជំនាញពាក់ព័ន្ធទាំងអស់ត្រូវសហការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៧ :** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តជាគតិយុត្តិ ចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ